# បច្ចេកទេសចិញ្ចឹមបង្កង ក្នុងស្រះ



មជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍន៍វារីវប្បកម្មទឹកសាប

បាទី ស្រុកពាមរក៏ ខេត្តព្រៃវែង

ឆ្នាំ ២០១១

# បច្ចេកទេសចិញ្ចឹមបង្កងក្នុងស្រះ

**រៀបរៀងដោយ៖**

**ជា ថារិទ្ធ** អនុប្រធានវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលសមុទ្រ

**សំ ណារិទ្ធ** អនុប្រធានមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍន៍វារីវប្បកម្មទឹកសាប

**ពិនិត្យ និងកែសម្រួលដោយ៖**

**សម នៅ** អគ្គនាយករង នៃរដ្ឋបាលជលផល

**មន្ត្រីបច្ចេកទេស** នាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម

រក្សាសិទ្ធិដោយ

**នាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម នៃរដ្ឋបាលជលផល**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

អាសយដ្ឋានលេខ ១៨៦ មហាវិថីព្រះនរោត្តម ប្រអប់សំបុត្រ ៨៣៥

រាជធានីភ្នំពេញ

ទូរស័ព្ទ-ទូរសារ (៨៥៥) ២៣ ៩៩ ៣២ ២៤

# មាតិកាអត្ថបទ


**សេចក្តីផ្តើម**.....-១-

**បច្ចេកទេសចិញ្ចឹមបង្កងក្នុងស្រះ**.....-២-

**១. ការរៀបចំស្រះសម្រាប់ចិញ្ចឹម**.....-៣-

១-១- ទីតាំងជីកស្រះ.....-៣-

១-២- លក្ខណៈស្រះ.....-៣-

១-៣- គុណភាពទឹក.....-៤-

១-៤- សម្ភារៈប្រើប្រាស់.....-៥-

១-៥- ការរៀបចំស្រះ.....-៥-

**២. ការជ្រើសរើសកូនបង្កងពូជ និងរបៀបលែង**.....-៨-

២-១- ការជ្រើសរើសកូនបង្កងពូជ.....-៨-

២-២- របៀបលែងកូនបង្កងដាក់ចិញ្ចឹម.....-៩-

**៣. ចំណី និងរបៀបផ្តល់ចំណី**.....-១១-

៣-១- ចំណី.....-១១-

៣-២- របៀបផ្តល់ចំណី.....-១៣-

**៤. ការគ្រប់គ្រងគុណភាពទឹកស្រះ**.....-១៦-

ក-ការផ្លាស់ប្តូរទឹក.....- ១៦-

ខ-កត្តាសំខាន់ៗ នៃគុណភាពទឹក.....-១៧-

**៥. ការប្រមូលផលបង្កង**.....-១៩-

# សេចក្ដីផ្ដើម

បង្កងស្ថិតក្នុងអំបូរ Palaemonidae ពូជ *Macrobrachium* និងស្ថិតក្នុងប្រភេទ *Macrobrachium rosenbergii*។ បង្កងរស់នៅ និងធំធាត់ក្នុងមជ្ឈដ្ឋានទឹកសាប ប៉ុន្តែបន្តពូជនៅតំបន់ទឹកភ្លាវ។ បង្កងមាននៅតាមបណ្ដាប្រទេសដែលមានអាកាសធាតុក្ដៅ ដូចជាប្រទេសវៀតណាម កម្ពុជា ថៃឡង់ដ៍ ម៉ាឡេស៊ី ឥណ្ឌូនេស៊ី ហ្វីលីពីន ឥណ្ឌា។ល។ នៅប្រទេសកម្ពុជា បង្កងសម្បូរនៅតាមដងទន្លេមេគង្គក្នុងខេត្តព្រៃវែង កណ្ដាល និងខេត្តតាកែវ។ បង្កងជាប្រភេទទំនិញមានតម្រូវការខ្ពស់នៅលើទីផ្សារគ្រប់ទីកន្លែង ដែលជាហេតុញ៉ាំងឱ្យ រដ្ឋបាលជលផល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ យកចិត្តទុកដាក់រៀបចំឯកសារ" **បច្ចេកទេសចិញ្ចឹមបង្កងក្នុងស្រែ** "នេះឡើង និងខិតខំជំរុញឱ្យកសិករ និងវារីវប្បករទូទៅបង្កើនការចិញ្ចឹមបង្កង ដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារ ក្នុងគោលបំណងបង្កើនប្រាក់ចំណូលក្នុងគ្រួសារថែមទៀតផង។

## បច្ចេកទេសចិញ្ចឹមបង្កងក្នុងស្រះ

ដើម្បីចិញ្ចឹមបង្កងដោយជោគជ័យ ចាំបាច់ត្រូវយកចិត្តទុកដាក់លើកត្តាសំខាន់ ៣ យ៉ាងគឺៈ ការរៀបចំស្រះ ការគ្រប់គ្រងគុណភាពទឹក និងការផ្តល់ចំណី។

**រដូវកាលចិញ្ចឹមៈ** អាចចិញ្ចឹមបានពេញ ១ ឆ្នាំ អាស្រ័យដោយមានប្រភពទឹកគ្រប់គ្រាន់។

**វិធីសាស្រ្តចិញ្ចឹមៈ** ការចិញ្ចឹមបង្កងក្នុងស្រះមាន ៣ របៀបគឺការចិញ្ចឹមទ្រង់ទ្រាយតូច ឬ ជាលក្ខណៈគ្រួសារទ្រង់ទ្រាយមធ្យម និងទ្រង់ទ្រាយធំ ឬចិញ្ចឹមជាលក្ខណៈឧស្សាហកម្ម។

**-ការចិញ្ចឹមទ្រង់ទ្រាយតូច ឬជាលក្ខណៈគ្រួសារៈ** ជារបៀបចិញ្ចឹមដែលមិនចំណាយទុនច្រើនលើការទិញសម្ភារៈមកប្រើប្រាស់ ចំណី និងមិនទាមទារបច្ចេកទេសខ្ពស់។ ទិន្នផលអាចទទួលបានពី ២០០ ទៅ ៤០០ គីឡូក្រាម ក្នុង ១ ហិចតាក្នុង ១រដូវ រយៈពេលពី ៦ ទៅ ៨ ខែ។

**-ការចិញ្ចឹមទ្រង់ទ្រាយមធ្យមៈ** ស្រះត្រូវមានលក្ខណៈសមស្របតាមបច្ចេកទេស ទាមទារឱ្យមានបច្ចេកទេសក្នុងការចិញ្ចឹម និងចំណាយទុនច្រើន ដូចជាការទិញពូជ និងចំណី។ ទិន្នផលអាចទទួលបាន ពី ៦០០ ទៅ ១.៥០០គីឡូក្រាម ក្នុង ១ ហិចតា ក្នុង ១រដូវ រយៈពេលពី ៦ ទៅ ៨ ខែ។

**-ការចិញ្ចឹមទ្រង់ទ្រាយធំ ឬចិញ្ចឹមជាលក្ខណៈឧស្សាហកម្មៈ** ទាមទារត្រូវចំណាយទុនច្រើនលើការរៀបចំស្រះ ទិញកូនបង្កងពូជ ចំណី ទិញសម្ភារៈប្រើប្រាស់ ដូចជាម៉ាស៊ីនបូមទឹក ម៉ាស៊ីនបង្កើនអុកស៊ីសែន ។ល។ និងទីតាំងស្រះចិញ្ចឹមត្រូវសមស្របតាមលក្ខណៈបច្ចេកទេស មានផ្ទៃដីធំទូលាយ និងអនុវត្តបច្ចេកទេសខ្ពស់។ ទិន្នផលអាចទទួលបានពី ២.០០០ ទៅ ៤.០០០ គីឡូក្រាម ក្នុង ១រដូវ រយៈពេលពី ៦ ទៅ ៨ ខែ។

## ១.ការរៀបចំស្រះសម្រាប់ចិញ្ចឹម

### ១-១- ទីតាំងជីកស្រះ

-ស្រះគួរជីកនៅតំបន់មានប្រភពទឹកពេញមួយឆ្នាំ ជាប្រភេទទឹកសាប ស្អាតល្អ គ្មានជាតិពុល តំបន់គ្មានប្រើថ្នាំកសិកម្ម និងគ្មានកាកសំណល់ពីរោងចក្រ និងអាចធ្វើការផ្លាស់ប្តូរទឹកបានដោយងាយស្រួល ដោយប្រើម៉ាស៊ីនបូម ឬអាចបញ្ចូលទឹកតាមរយៈរបបទឹកជោរនាច។ យើងអាចជ្រើសរើសទីតាំងចិញ្ចឹមនៅតំបន់ទឹកសាប ឬ តំបន់ទឹកភ្លាវ ដែលមានកំហាប់អំបិលមិនលើសពី ១០ ភាគពាន់ ។

-ទីតាំងជីកស្រះ ជាប្រភេទដីល្បាយដីឥដ្ឋ ឬ លាយខ្សាច់តិចតួច ដើម្បីអាចរក្សាទឹកបានយូរ និងគ្មានជាតិជូរ ។

-ទីតាំងស្រះ ត្រូវនៅក្បែរផ្លូវគមនាគមន៍ និងត្រូវមានអគ្គិសនីគ្រប់គ្រាន់ជាពិសេសសម្រាប់ការចិញ្ចឹមទ្រង់ទ្រាយមធ្យម និងទ្រង់ទ្រាយធំ។

### ១-២- លក្ខណៈស្រះ

-ស្រះត្រូវមានរាងចតុកោណកែង មានផ្ទៃក្រឡាចាប់ពី ១.០០០ ម៉ែត្រការេឡើងទៅ (ឬអាចមានទំហំតូចជាងនេះក៏បានដែរ សម្រាប់ការចិញ្ចឹមទ្រង់ទ្រាយតូច) និងមានជម្រៅទឹកពី ១.២ ទៅ ១.៥ ម៉ែត្រ។ បាតស្រះត្រូវមានកម្រិតជម្រាលទៅជ្រុងម្ខាង ដើម្បីងាយស្រួលបញ្ចេញទឹកចោល។ នៅបាតស្រះត្រូវមានជីកប្រឡាយសម្រាប់នាំទឹកពីកន្លែងបញ្ចូលទឹករហូតដល់កន្លែងបញ្ចេញទឹកចោល។ ប្រឡាយគួរមានទទឹងពី ២ ទៅ ៣ ម៉ែត្រ និងត្រូវមានជម្រៅជ្រៅជាងបាតស្រះពី ១០ ទៅ ១៥ សង់ទីម៉ែត្រ។ បាតស្រះ ត្រូវមានភក់ ឬ មមោកតិច។